# ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ២០១៩-២០២៣

*សេចក្ដីសង្ខេបនៃការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ*

ភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩

<u>អ្នកចូលរួម៖</u> មានតំណាងចំនួន ៥៧រូប មកពីក្រសួងពាក់ព័ន្ធ សភាជាតិ និងគណៈកម្មាធិការ ចូលរួមមកពីស្ថាប័នដៃគូអភិវឌ្ឍទ្វេភាគី ។

<u>សេចក្ដីផ្ដើម៖</u> ធនាគារពិភពលោកបើកកិច្ចពិគ្រោះយោបល់នេះដោយធ្វើការរៀបរាប់សង្ខេបពីអំពីបរិបទរបស់ប្រទេស និងអាទិភាពនានាក្នុងកិច្ចការអភិវឌ្ឍន៍ ដូចត្រូវបានរកឃើញតាមរយៈការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ (SCD) ព្រមទាំងសំណើវិស័យត្រូវផ្ដោតយកចិត្តទុកដាក់សម្រាប់ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ដែលស្របតាមអាទិភាពរបស់យុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាលកម្ពុជា។ បណ្ដាវិស័យត្រូវផ្ដោតយកចិត្តទុកដាក់ក្នុងក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) រួមមាន៖ ១) លើកកម្ពស់ប្រសិទ្ធផលរបស់រដ្ឋ និងជំរុញការអភិវឌ្ឍវិស័យឯកជន, ២) ជំរុញការអភិវឌ្ឍមនុស្ស, ៣) កែលម្អវិស័យកសិកម្ម និងពង្រឹងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិឱ្យកាន់តែប្រសើរ និងមូលបទអន្តរវិស័យស្ដីពីការពង្រឹងអភិបាលកិច្ច ស្ថាប័ន និងការចូលពាក់ព័ន្ធរបស់ពលរដ្ឋ។ បន្ថែមលើមាគ៌ាដែលត្រូវបានគ្រួសត្រាយដោយការវិនិច្ឆ័យស្ថានភាពប្រទេសមានលក្ខណៈជាប្រព័ន្ធ (SCD) និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា មានគោលដៅពិចារណាមើលអំពីឧត្តមភាពប្រៀបធៀបនៃវិស័យគម្រោងអនុវត្តនានារបស់ក្រុមធនាគារពិភពលោក។ បន្ទាប់មក អ្នកចូលរួមបានធ្វើការពិភាក្សាសំណួរដែលក្រុមធនាគារពិភពលោកបានលើកឡើងនៅក្នុងកិច្ចពិគ្រោះនោះ។

<u>បញ្ហាធំៗដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សាមាន៖</u> ហេដ្ឋារចនាសម្ព័ន្ធជនបទ សេដ្ឋកិច្ចឌីជីថល ការគាំពារសង្គម ការប្រែប្រួលអាកាសធាតុ យេនឌ័រ និងសហគ្រាសធុនតូចនិងមធ្យម។

| វិស័យដែលត្រូវបានលើកយកមកពិភាក្សា | ចំណុចគោលសំខាន់ៗដែលបានលើកឡើង |
|---|---|
| **តើអ្វីខ្លះទៅជាបញ្ហាប្រឈមនិងភាពចាំបាច់បន្ទាន់ជាងគេនៅក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ?** | • ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចគឺជាបញ្ហាមួយ។ ប្រទេសកម្ពុជាត្រូវធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន ធ្វើទំនើបកម្មវិស័យជាច្រើន និងស្វែងរកមធ្យោបាយដើម្បីបន្ថែមតម្លៃទៅលើផលិតផលសេដ្ឋកិច្ច។<br>• មានសារៈសំខាន់សម្រាប់រដ្ឋាភិបាលក្នុងការកំណត់អត្តសញ្ញាណមុខសញ្ញាបង្កើនល្បឿនកំណើនសេដ្ឋកិច្ច ឧទាហរណ៍នៅតាមវិស័យដែលការវិនិយោគតិចតួចអាចនាំមកនូវកំណើនសេដ្ឋកិច្ចបានកាន់តែធំធេងថែមទៀត។<br>• ថ្វីបើកម្ពុជាសម្រេចបានយ៉ាងល្អនៅក្នុងការកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏ការវិនិយោគក្នុងកិច្ចគាំពារសង្គមនៅតែមានកម្រិតទាបនៅឡើយ។ រដ្ឋាភិបាលបាននិងកំពុងវិនិយោគយ៉ាងច្រើនក្នុងវិស័យកសាងមូលធនមនុស្ស ដូចជាការអប់រំ និងសុខភាពជាដើម ប៉ុន្តែឥឡូវនេះការគាំពារសង្គមនឹងដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការកសាងមូលធនមនុស្សដែរ។ ទោះជាយ៉ាងណាក៏ដោយ ការគាំពារសង្គមគឺជាវិស័យថ្មីមួយ ហើយវាមានតម្រូវការច្រើនជាងវិស័យធនធានមនុស្សជាមូលដ្ឋានផ្សេងៗទៀត។<br>• ផ្លូវ  និងលទ្ធភាពចូលទៅកាន់ទីជនបទនៅតែជាបញ្ហាធំមួយ។<br>• ស្ត្រីនិងកុមារងាយរងគ្រោះខ្លាំងជាងគេ និងរងផលប៉ះពាល់ច្រើនលើសលប់ពីបញ្ហាច្រើនបែបយ៉ាងនៅទីជនបទ ដូចជាគ្រោះមហន្តរាយធម្មជាតិ និងបញ្ហាទឹកនិងអនាម័យជាដើម។<br>• ប្រទេសកម្ពុជាងាយរងគ្រោះដោយហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ ទឹកជំនន់ និងភាពរាំងស្ងួត អាចបង្កឱ្យមានការលំបាកដល់ប្រជាជននៅតំបន់ជនបទក្នុងការស្វែងរកទទួលបានសេវាសំខាន់ៗ។<br>• វិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍនៅកម្ពុជានាពេលបច្ចុប្បន្នរួមមានការអប់រំ និងការកសាងសមត្ថភាព បញ្ហាដីធ្លី សុខាភិបាល ហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងគ្រឹះស្ថានហិរញ្ញវត្ថុ។<br>• វិស័យឯកជននឹងក្លាយជាគន្លឹះក្នុងការឈានទៅសម្រេចបាននូវគោលដៅរបស់រដ្ឋាភិបាលដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ហើយសហគ្រាសធុនតូចនិងមធ្យមនឹងដើរតួនាទីមួយសំខាន់ ក្នុងទិសដៅនេះ។ សហគ្រាសខ្នាតតូច និងមធ្យម តំណាងឱ្យភាគរយធំមួយនៃកម្លាំងពលកម្មនៅក្នុងសេដ្ឋកិច្ច។ ខណៈដែលប្រទេសកម្ពុជាបានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងសហគ្រាសធំៗច្រើនក៏ពិតមែន ប៉ុន្តែសហគ្រាសធុនតូចនិងមធ្យមនៅតែមានការអភិវឌ្ឍតិចតួចនៅឡើយ។ |
| **តើមានអ្វីខ្លះជាវិស័** | • អ្នកចូលរួមជាច្រើននៅក្នុងកិច្ចពិគ្រោះយោបល់នេះបានយល់ស្របថា បណ្តាអាទិភាពដែលធនាគារពិភពលោកបានស្នើឡើងសម្រាប់ក្រប |

| | |
|---|---|
| **យអាទិភាពសម្រាប់ក្រុមធនាគារពិភពលោកបន្តជួយឧបត្ថម្ភនៅក្នុងអំឡុងពេល៥ឆ្នាំខាងមុខ? មានអ្វីខ្លះដែលក្រុមធនាគារពិភពលោកគួរបន្តសកម្មភាពជួយបន្ថែមទៀត ឬបន្ថយសកម្មភាពវិញ?** | ខណ្ឌភាពជាដៃគូសម្រាប់ប្រទេស (CPF) ពិតជាសមស្របនៅក្នុងបរិបទប្រទេសនាពេលបច្ចុប្បន្ន បើទោះបីជាមានការលើកឡើងសំណើបន្ថែមមួយចំនួនទៀតក៏ដោយ។<br>• ជាទូទៅ ចំណេះដឹង ការគាំទ្រផ្នែកបច្ចេកទេស/ការគាំទ្រផ្នែកផ្តល់ប្រឹក្សា ការគាំទ្រផ្នែកគោលនយោបាយ ការរៀបចំក្របខណ្ឌ និងអានុភាពផ្នែកហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ដទៃទៀតរបស់ធនាគារពិភពលោក ទទួលការវាយតម្លៃខ្ពស់ក្នុងគ្រប់វិស័យទាំងអស់។<br><br>*ការអភិវឌ្ឍមនុស្ស*<br>• ធនាគារពិភពលោកគួរធ្វើយ៉ាងណាឱ្យមានការឆ្លុះបញ្ចាំងទិដ្ឋភាពយេនឌ័រឱ្យបានច្បាស់លាស់នៅក្នុងគម្រោងទាំងអស់ ហើយឱ្យបញ្ហាយេនឌ័រត្រូវបានបញ្ជ្រាបនៅតាមគ្រប់ផ្នែក ដោយហេតុថាវាជាចំណុចសំខាន់នៅក្នុងវិស័យទាំងអស់។<br>• ការកសាងសមត្ថភាពមានច្រើនកម្រិត ប៉ុន្តែធនាគារពិភពលោកស្ថិតក្នុងស្ថានភាពរឹងមាំមួយក្នុងការជួយគាំទ្រការអប់រំកម្រិតឧត្តមសិក្សា។ យើងមានគម្រោងរួចហើយនៅក្នុងវិស័យនេះ ហើយធនាគារពិភពលោកអាចបន្តធ្វើឱ្យបានច្រើនថែមទៀតនៅពេលអនាគត។<br>• ធនាគារពិភពលោកគួរតែគាំទ្រការគាំពារសង្គម - នេះប្រហែលជាមិនមែនជាទម្រង់ជាការផ្តល់ប្រាក់កម្ចីនោះទេ ប៉ុន្តែក្នុងការគាំទ្របច្ចេកទេសដោយការចែករំលែកជំនាញ ដើម្បីយកទៅរៀបចំក្របខណ្ឌ ធានានិរន្តភាព និងទាក់ទាញធនធានពីប្រភពផ្សេងទៀត។ តាមរបៀបនេះ ធនាគារពិភពលោកអាចជួយរដ្ឋាភិបាលរៀបចំផែនការដើម្បីដោះស្រាយបញ្ហានេះដោយខ្លួនឯងឱ្យកាន់តែមានប្រសិទ្ធិភាពនាពេលអនាគត។<br><br>*អភិបាលកិច្ច និងសេដ្ឋកិច្ច*<br>• បច្ចុប្បន្នកំណែទម្រង់វិស័យសាធារណៈ និងកំណែទម្រង់រាជការស៊ីវិលកំពុងដំណើរការ ហើយគួរតែមានការខិតខំប្រឹងប្រែងមួយចំនួនទៅលើការកសាងសមត្ថភាពមន្ត្រីរាជការ ដើម្បីធានាឱ្យមានការផ្តល់សេវាសាធារណៈកាន់តែល្អប្រសើរឡើង។ ធនាគារពិភពលោកផ្តោតកម្មវិធីរបស់ខ្លួនទៅលើគណនេយ្យភាពក៏ពិតមែន ប៉ុន្តែការកសាងសមត្ថភាពក៏គួរតែត្រូវបានយកទៅគិតគូរផងដែរ។<br>• ធនាគារពិភពលោកគួររួមចំណែកគាំទ្រដល់ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការ។<br>• មានការស្នើឡើងឱ្យធនាគារពិភពលោកជួយដល់ការធ្វើធុរកិច្ច ជាពិសេសក្នុងការកាត់បន្ថយថ្លៃចំណាយលើការបង្កើតគ្រឹះស្ថានធុរកិច្ច និងថ្លៃចំណាយលើប្រតិបត្តិការធុរកិច្ច។ (រួមទាំងបរិយាកាសធុរកិច្ច ការសម្របសម្រួលពាណិជ្ជកម្ម តម្លៃអគ្គិសនី និងកត្តាផ្សេងៗទៀត)។<br>• ការងាររបស់ធនាគារពិភពលោកពាក់ព័ន្ធសហគ្រាសធុនតូចនិងមធ្យមគួរផ្តោតទៅលើការថាតើធ្វើដូចម្តេចឱ្យវាទៅជាផ្លូវការ និងគ្រប់គ្រងវាដូចម្តេចឱ្យបានកាន់តែប្រសើរឡើង លទ្ធភាពទទួលបានហិរញ្ញប្បទាន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យសហគ្រាសធុនតូចនិងមធ្យមអាច |

| | |
|---|---|
| | ដើរតួនាទីនៅក្នុងកំណើនសេដ្ឋកិច្ចបាន។<br>• ធនាគារពិភពលោកគួរតែគាំទ្រដល់វិស័យសេដ្ឋកិច្ចឌីជីថលព្រោះវាជាកត្តាជំរុញកំណើនសេដ្ឋកិច្ច។<br>• វិស័យ ICT គួរត្រូវបានរៀបចំអភិវឌ្ឍន៍ឱ្យទៅជាមធ្យោបាយដើម្បីលើកកម្ពស់តម្លាភាព និងប្រសិទ្ធភាពនៃគម្រោង ឬ រដ្ឋបាលសាធារណៈ។<br>• ធនាគារពិភពលោកអាចជួយលើបញ្ហាបន្ទាន់នៃការធ្វើនគរូបនីយកម្ម - ក្នុងនោះមានកំណែទម្រង់គោលនយោបាយ ការកសាងសមត្ថភាព និងការកាត់បន្ថយផលប៉ះពាល់លើប្រទេសទាំងមូល។<br><br>*ការអភិវឌ្ឍជនបទ*<br>• លើកទឹកចិត្តឱ្យមានការគាំទ្រពីធនាគារពិភពលោកសម្រាប់ការអភិវឌ្ឍបណ្តាញការដឹកជញ្ជូនតាមជនបទ និងការផ្គត់ផ្គង់ទឹក។<br>• ការអភិវឌ្ឍជនបទជាវិស័យល្អមួយសម្រាប់ធនាគារពិភពលោកចូលពាក់ព័ន្ធ ដូចជា ការប្រើដីធ្លី ការធ្វើសម្បទានដី និងការដោះមីន។<br><br>*បរិស្ថាន និងកសិកម្ម*<br>• នៅលើរបៀបវារៈកសិកម្ម អ្នកចូលរួមបានលើកឡើងថា ជាការសំខាន់ដែលធនាគារពិភពលោកផ្តល់ការគាំទ្រដល់ការធ្វើពាណិជ្ជកម្មនៃផលិតផលកសិកម្មផងដែរ កុំជួយត្រឹមតែការធ្វើពិពិធកម្មកសិកម្ម។<br>• ធនាគារពិភពលោកគួរតែសម្របសម្រួលការវិនិយោគទុនសាធារណៈ និងឯកជនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ឧស្សាហកម្មកសិកម្ម។<br>• គម្រោងទាំងអស់គួរតែមានការគិតគូរអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ |
| **តើមានអ្វីខ្លះដែលអាចជាបញ្ហាប្រឈមគួរឱ្យកត់សម្គាល់សម្រាប់ការអនុវត្ត ហើយថាតើបញ្ហាប្រឈមទាំងនោះអាចត្រូវបាន** | • ភាពធន់ទ្រាំអាកាសធាតុនៃគម្រោងគឺជាបញ្ហាប្រឈមមួយ - ជួនកាលឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុធ្វើឱ្យគម្រោងមិនសូវមាននិរន្តរភាព។<br>• តាមការយល់ឃើញ អាចមានការខ្វះការភ្ជាប់ទាក់ទងគ្នាខ្លះរវាងដៃគូអភិវឌ្ឍន៍ ដែលអាចបណ្តាលឱ្យមានចន្លោះប្រហោង ឬការធ្វើសកម្មភាពត្រួតជាន់គ្នា។ មិនមែនដៃគូអភិវឌ្ឍន៍ទាំងអស់សុទ្ធតែធានាធ្វើឱ្យមានអ្នកមូលដ្ឋានមានសមត្ថភាពដើម្បីទ្រទ្រង់បន្តការងារទៅមុខបានវែងឆ្ងាយទេ បន្ទាប់ពីពេលគម្រោងត្រូវបានបញ្ចប់។<br>• ការសម្របសម្រួលជាមួយវិស័យឯកជនក៏ជាបញ្ហាប្រឈមមួយផងដែរ។ ភាពជាដៃគូដ៏រឹងមាំមួយនឹងអាចជួយប្រមូលផ្តុំ និងតម្រង់ការវិនិយោគឯកជនឱ្យសម្របខ្លួនតាមអាទិភាពនៃការអភិវឌ្ឍបាន។ |

| | |
|---|---|
| **កាត់បន្ថយដោយរបៀបណាខ្លះ?** | • កង្វះសមត្ថភាពរបស់មន្ត្រីរាជការអាចបង្កបញ្ហាក្នុងការអនុវត្តគម្រោង។ ការតាមដានជាទៀងទាត់និងការណែនាំស្តីពីការអនុវត្ត អាចមានប្រយោជន៍សម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រឈមបែបនេះ។<br>• ការកៀងគរធនធានអាចជារឿងប្រឈមមួយ ហើយការធានាថាវាត្រូវបានយកទៅប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពក៏ជារឿងប្រឈមមួយទៀតដែរ។ ពេលវេលាសម្រាប់ធ្វើការឆ្លើយតបអាចជាបញ្ហាមួយ។ ប្រហែលជា ICT អាចជាវិធីមួយល្អដើម្បីគ្រប់គ្រងគម្រោងថវិកាឱ្យបានល្អប្រសើរ។<br>• ក្រសួងពាក់ព័ន្ធនឹងទទួលបានអត្ថប្រយោជន៍ពីការសម្របសម្រួលកាន់តែប្រសើរឡើង សម្រាប់ការរៀបចំថវិកាគាំទ្រផ្នែកយេនឌ័រ និងប្រែប្រួលអាកាសធាតុ។ |
| **អត្ថាធិប្បាយផ្សេងៗទៀត** | • វាអាចមានប្រយោជន៍សម្រាប់រដ្ឋាភិបាលដែរប្រសិនបើធនាគារពិភពលោកអាចបែងចែកឱ្យច្បាស់ពីភាពខុសគ្នានៅក្នុង CPF ថាវិស័យណាខ្លះកំពុងដំណើរការ ឬ ជាការបន្តការងារពីមុន និងអ្វីខ្លះដែលជាសកម្មភាពថ្មី។<br>• ជនពិការគួរត្រូវបានចាត់ទុកថាជាក្រុមងាយរងគ្រោះ ឬ ជាគោលដៅនៅក្នុងប្រតិបត្តិការរបស់ធនាគារពិភពលោក។<br>• អ្នកចូលរួមក្នុងកិច្ចពិគ្រោះយោបល់បានសម្តែងចំណាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែមទៀតអំពីសូចនករអភិវឌ្ឍន៍ជំនួស (ក្រៅពី GDP/GNI ក្នុងមនុស្សម្នាក់)។ |